# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៩

LECTURE 9

## រដ្ឋ (ដែនដីនៃរដ្ឋ)

STATE (TERRITORY OF STATE)

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្អែកទី១ សេចក្ដីផ្ដើម
- ផ្អែកទី២ ដែនដីគោក
    - សញ្ញាណទូទៅ
    - ការកំណត់ព្រំដែនដីគោក
- ផ្អែកទី៣ ដែនទឹក (ដែនសមុទ្រ)
    - សញ្ញាណទូទៅ
    - ការកំណត់ព្រំដែនទឹក
- ផ្អែកទី៤ ដែនអាកាស
    - សញ្ញាណទូទៅ
    - ការកំណត់ព្រំដែនអាកាស

# កម្មវត្ថុនៃមេរៀន

មេរៀនស្ដីពីរដ្ឋ (ដែនដីនៃរដ្ឋ) មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- សមាសភាពដែនដីរបស់រដ្ឋមានអ្វីខ្លះ?
- ការកំណត់ព្រំដែនគោករបស់រដ្ឋ
- ការកំណត់ និងបែងចែកដែនសមុទ្រ
- ការកំណត់ដែនអាកាស និង
- របបគតិយុត្តនៃសមាសភាពដែនដី

# ផ្នែកទី១ សេចក្តីផ្តើម

ដូចអ្នកសិក្សាបានដឹងហើយថា នៅក្នុងមេរៀនទី៨ ស្តីពីរដ្ឋ (ធាតុផ្សំនៃរដ្ឋ) យើងបានសិក្សាពីធាតុផ្សំនៃរដ្ឋ ដែលក្នុងនោះមានធាតុផ្សំមួយគឺ ដែនដីនៃរដ្ឋ។ នៅក្នុងមេរៀនេះ យើងនឹងសិក្សាលម្អិតពីសមាសភាពដែនដីនៃរដ្ឋ ដែលក្នុងនោះរួមមាន ដែនដីគោក ដែនទឹក (ដែនសមុទ្រ) និងដែនអាកាស។

# ផ្នែកទី១ សេចក្ដីផ្ដើម

នៅលើពិភពលោកយើងនេះ បូរណភាពដែនដីត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង ជាពិសេសទៅទៀតវាត្រូវបានបញ្ញត្តនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ក៏ដូចត្រូវបានបញ្ញត្តនៅក្នុងច្បាប់កំពូលរបស់រដ្ឋ ថែមទៀតផង។ ដូច្នេះ ការសិក្សាពីការកំណត់អំពីដែនដីរបស់រដ្ឋពិតជាមានសារៈសំខាន់ខ្លាំងណាស់។

# ផ្នែកទី២ ដែនដីគោក

- សញ្ញាណទូទៅ

ដែនដីគោក ជាផ្ទៃដីទាំងអស់ដែលជាកម្មសិទ្ធិរបស់រដ្ឋ ហើយដែលអាចត្រូវបាន ហ៊ុំព័ទ្ធទៅដោយខ្សែបន្ទាត់ព្រំដែនគោក និងព្រំដែនទឹក (ដែនសមុទ្រ)។ ដូចដែលបានលើកឡើងនៅក្នុងមេរៀនទី៨ រដ្ឋមួយចំនួនអាចនឹងពុំមានព្រំដែនទឹកទេ។

# ផ្នែកទី២ ដែនដីគោក

- សញ្ញាណទូទៅ

ដែនដីគោករបស់រដ្ឋ អាចនៅជាប់គ្នា ឬ ក៏អាចនៅដាច់ពីគ្នា ហើយក៏អាចនៅជិតគ្នា ឬ ក៏អាចនៅឆ្ងាយពីគ្នា ឧទាហរណ៍ ប្រទេសឥណ្ឌូណេស៊ី ជារដ្ឋដែលកើតឡើងដោយប្រជុំកោះជាច្រើន និងសហរដ្ឋអាមេរិក ជារដ្ឋដែលមានដែនដីនៅដាច់ឆ្ងាយពីគ្នា ជាអាទ៍។

# ផ្នែកទី២ ដែនដីគោក

- សញ្ញាណទូទៅ

ក្នុងករណី ដែលមានការបាត់បង់នូវដែនដីរបស់ខ្លួនមួយផ្នែក ឬ មួយភាគ គឺពុំជះឥទ្ធិពលទៅដល់អត្ថិភាពថារដ្ឋនោះទេ វាអាចកើតឡើងដោយសារតែមានការឈ្លានពាន ការដោះដូរទឹកដី សំខាន់ឲ្យតែរដ្ឋនោះអាចរក្សាឲ្យបាននូវដែនដីខ្លួនមួយចំណែកណាមួយ។

# ផ្នែកទី២ ដែនដីគោក

- សញ្ញាណទូទៅ

បញ្ហាបូរណភាពទឹកដី និងខ្សែបន្ទាត់ព្រំដែនត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង។ ដូច្នេះ ការកំណត់ព្រំដែនរបស់រដ្ឋគឺមានសារៈសំខាន់ណាស់។ តើការកំណត់ព្រំដែនដីគោករបស់រដ្ឋ គេអាចកំណត់តាមមធ្យោបាយណាខ្លះ?

# ផ្នែកទី២ ដែនដីគោក

- ការកំណត់ព្រំដែនដីគោក

ខ្សែបន្ទាត់ព្រំដែនដីគោក គឺជាខ្សែបន្ទាត់តាមផ្លូវច្បាប់ដែលបញ្ជាក់ពីការកំណត់ដែនដី និងចែកដែនដីនោះចេញពីដែនដីរបស់រដ្ឋផ្សេងៗទៀត ព្រមទាំងចែកដែនដីនោះចេញពីលំហអាកាសអន្តរជាតិ ផងដែរ។

# ផ្នែកទី២ ដែនដីគោក

- ការកំណត់ព្រំដែនដីគោក

ព្រំប្រទល់ដីគោក អាចត្រូវបានកំនត់តាមមធ្យោបាយច្រើនយ៉ាងដូចជា ការកំណត់ព្រំដែនតាមឆន្ទៈនយោបាយ (សន្ធិសញ្ញា) ការកំណត់តាមលក្ខណៈបច្ចេកទេស ការកំណត់ដោយគោរពគោលការណ៍មិនកែប្រែ និងការកំណត់ព្រំដែនតាមគោលការណ៍កាន់កាប់ជាក់ស្តែង។

# ផ្នែកទី២ ដែនដីគោក

- ការកំណត់ព្រំដែនដីគោក

ការកំណត់ព្រំដែនតាមឆន្ទៈនយោបាយៈ គឺជាការកំណត់តាមរយៈការព្រមព្រៀងគ្នាជាលាយលក្សអក្សរ រវាងរដ្ឋដែលជាភាគី ជាទូទៅគេតែហៅថា សន្ធិសញ្ញាព្រំដែន ពោលគឺរដ្ឋព្រមព្រៀងទទួលស្គាល់ ដោយភ្ជាប់ជាមួយនូវភស្តុតាងជាក់លាក់នូវខ្សែបន្ទាត់ព្រំដែនរៀងៗខ្លួន ។

# ផ្នែកទី២ ដែនដីគោក

- ការកំណត់ព្រំដែនដីគោក

<u>ការកំណត់ព្រំដែនតាមលក្ខណៈបច្ចេកទេស:</u> គឺជាប្រតិបត្តិការដែលត្រូវអនុវត្តជាក់ស្តែងក្រោយពីមានការព្រមព្រៀងគ្នា ឬក្រោយពីបានចុះសន្ធិសញ្ញាជាមួយគ្នារួចមក។ រដ្ឋជាភាគីត្រូវបង្កើតគណៈកម្មាការព្រំដែនរៀងៗខ្លួន ហើយចុះទៅរៀបចំបោះបង្គោលព្រំដែននៅលើដែនដីពិត។

# ផ្នែកទី២ ដែនដីគោក

- ការកំណត់ព្រំដែនដីគោក

គោលការណ៍មិនកែប្រែ UTI-POSSIDETIS: គឺជាគោលការណ៍នៃការកំណត់ព្រំដែន ដែលបន្សល់ទុកពីម្ចាស់អាណានិគមន៍ ហើយរដ្ឋដែលមានព្រំដែនបន្សល់ពីអាណានិគមន៍ព្រមទទួលស្គាល់ថាបែបនេះ។

# ផ្នែកទី២ ដែនដីគោក

- ការកំណត់ព្រំដែនដីគោក

គោលការណ៍កាន់កាប់ជាក់ស្តែង: គឺជាការកំណត់ព្រំដែនដីគោក ផ្អែកលើការកាន់កាប់ជាក់ស្តែងរបស់រដ្ឋណាមួយដោយភ្ជាប់ជាមួយនូវភស្តុតាងបញ្ជាក់ច្បាស់លាស់ មានន័យថា រដ្ឋអាចប្រកាន់យកនូវដីណាមួយជារបស់ខ្លួន។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- សញ្ញាណទូទៅ

ដែទឹក ឬ ដែនសមុទ្រ គឺជាដែនដែលស្ថិនក្រោមអធិបតេយ្យរបស់រដ្ឋ ហើយរដ្ឋអនុវត្តនូវដែនសមត្ថកិច្ចដូចនៅលើដែនដីគោកដែរ។ ការអនុវត្តសមត្ថិច្ចរបស់រដ្ឋនេះ អាចមានការប្រែប្រួលពីសណ្ឋាននៃដែនសមុទ្រនីមួយៗ ពោលគឺសមត្ថកិច្ចថយចុះពីដែនសមុទ្រក្នុង ទៅដែនសមុទ្រខាងក្រៅ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- សញ្ញាណទូទៅ

សមត្ថកិច្ចរដ្ឋ មានការថយចុះទៅតាមប្រភេទនៃដែនសមុទ្រ គឺចាប់ពីដែនទឹកក្នុងដល់តំបន់ខ្ពង់រាបបាទសមុទ្រ។ តាមអនុសញ្ញាស្តីពីនីតិសមុទ្រ ដែនសមុទ្ររបស់រដ្ឋត្រូវបែងចែកជា ៥ រួមមាន ដែនទឹកក្នុង សមុទ្រដែនដី តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាទសមុទ្រ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- សញ្ញាណទូទៅ

ការកំណត់ដែនសមុទ្រអាចអនុវត្តទៅបាន លុះណាមានការកំណត់អំពីខ្សែបន្ទាប់មូលដ្ឋានជាមុនសិន។ អ្វីទៅជាខ្សែបន្ទាត់មូលដ្ឋាន? ខ្សែបន្ទាត់មូលដ្ឋាន គឺជាខ្សែបន្ទាត់រាយតាមបណ្តោយឆ្នេរ សម្រាប់ធ្វើការកំណត់ដែនសមុទ្ររដ្ឋ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- សញ្ញាណទូទៅ

ខ្សែបន្ទាត់មូលដ្ឋានមានចំនួន២ គឺខ្សែបន្ទាប់មូលដ្ឋានធម្មតា និងខ្សែបន្ទាត់មូលដ្ឋានត្រង់។ ខ្សែបន្ទាត់មូលដ្ឋានធម្មតាប្រើសម្រាប់កំណត់តំបន់ឆ្នេរដែលពុំមានភាពរឆេករឆ្វេតខ្លាំង និងខ្សែបន្ទាប់មូលដ្ឋានត្រង់ ប្រើសម្រាប់កំណត់តំបន់ឆ្នេរដែលរឆេករឆ្វេតខ្លាំង មានកញ្ចុំកោះច្រើន ជាអាទ៍។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

**<u>ដែនទឹកក្នុង</u>** ជាលំហរសមុទ្រដែលស្ថិតនៅពីខាងក្នុងនៃខ្សែបន្ទាត់មូលដ្ឋាន ដែលជាចន្លោះពីដីគោក និងខ្សែបន្ទាត់មូលដ្ឋាន ដែលក្នុងនោះអាចមានដូចជា កំពង់ផែ ឆក សមុទ្របិទ ឬ ពាក់កណ្តាលបិទ។ ដែនទឹកក្នុងរដ្ឋអនុវត្តសមត្ថកិច្ចដូចដែនដីគោកដែរ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

**សមុទ្រដែនដី** ជាលំហារសមុទ្រចាប់ពីខ្សែបន្ទាត់មូលដ្ឋានចូលទៅក្នុងសមុទ្រមានចម្ងាយ១២ម៉ាយ។ កាលពីសម័យដើម រដ្ឋកំណត់ដែនសមុទ្ររបស់ខ្លួនដោយការប្រើកាំភ្លើងត្បាល់បាញ់ចូលទៅក្នុងសមុទ្រ ប្រសិនបើគ្រាប់កាំភ្លើងធ្លាក់នៅត្រង់ណា គេសន្មត់ត្រង់នោះជាដែនសមុទ្ររបស់រដ្ឋ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

• ការកំណត់ព្រំដែនទឹក

**សមុទ្រដែនដី** នៅក្នុងលំហរនេះ រដ្ឋជាម្ចាស់ដែនសមុទ្រអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួនបានពេញលេញទាំងផ្នែកសេដ្ឋកិច្ច និងទាំងផ្នែកសន្តិសុខ។ រដ្ឋម្ចាស់ដែនសមុទ្រ ជាប់កាតព្វកិច្ចតែមួយគត់ គឺមិនអាចហាមឃាត់ការធ្វើនាវាចរស៊ីវិលឆ្លងកាត់ដោយសេរី និងសន្តិភាព។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

**តំបន់តភ្ជាប់** ជាលំហារសមុទ្រដែលមានចំងាយ ១២ម៉ាយពីសមុទ្រដែនដី ហើយបើគិតពីខ្សែបន្ទាត់មូលដ្ឋានមានចំងាយ ២៤ម៉ាយ។ នៅក្នុងតំបន់តភ្ជាប់ រដ្ឋម្ចាស់ដែនសមុទ្រមិនអាចអនុវត្តនូវអធិបតេយ្យរបស់ខ្លួនបានពេញលេញនោះទេ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

**តំបន់តភ្ជាប់** រដ្ឋអាចអនុវត្តសមត្ថកិច្ចខាងត្រួតពិនិត្យក្នុងទិសដើម្បីបង្ក្រាប និងបង្ការនូវបទល្មើសទាំងឡាយដែលអាចនឹងកើតមានឡើយ ដូចជាការ រត់ពន្ធ ការដឹកជញ្ជូនជាតិពុល ឬដូចជាការជួញដូរមនុស្ស ជាអាទិ៍។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

<u>**តំបន់សេដ្ឋកិច្ចផ្តាច់មុខ**</u> ជាលំហរសមុទ្រដែលមានចំងាយ ២០០ម៉ាយ ពីខ្សែបន្ទាត់មូលដ្ឋាន ឬ មានចំងាយ១៨២ម៉ាយ ពីសមុទ្រដែនដី ឬ មានចំងាយ១៧៦ម៉ាយពីតំបន់តភ្ជាប់។ រដ្ឋម្ចាស់ដែនសមុទ្រ អាចទាញយកផលប្រយោជន៍ជាច្រើន ពីលំហរសមុទ្រនេះ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

**<u>តំបន់សេដ្ឋកិច្ចផ្ដាច់មុខ</u>** នៅក្នុងតំបន់នេះ រដ្ឋអាចអនុវត្តនូវសមត្ថកិច្ចរបស់ខ្លួនបានមួយចំនួនដូចជា ការធ្វើអាជីវកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស និងការគ្រប់គ្រងនូវធនធានបាតសមុទ្រ ជាអាទ៍។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

ខ្ពង់រាបបាតសមុទ្រ គឺមានបាតសមុទ្រ និងដីក្រោមបាតសមុទ្ររបស់រដ្ឋជាប់ឆ្នេរ ដែលវាអាចលយនៃដីរបស់រដ្ឋចូលទៅក្នុងសមុទ្ររហូតដល់ជំរាលដ៏ជ្រៅនៃបាតសមុទ្រ។ ខ្ពង់រាបបាតសមុទ្រអាចនៅពីក្រោមតំបន់សេដ្ឋកិច្ចផ្តាច់មុខ និង សមុទ្រអន្តរជាតិអាស្រ័យទៅតាមសណ្ឋាននៃឆ្នេរសមុទ្រនោះ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

• ការកំណត់ព្រំដែនទឹក

ខ្ពង់រាបបាតសមុទ្រ ទោះជាជំរាលដ៏ជ្រៅនៃបាតសមុទ្រមានចំងាយឆ្ងាយយ៉ាងណាក៏ដោយ អនុសញ្ញាស្តីពីនីតិសមុទ្រឆ្នាំ ១៩៨២ អនុញ្ញាតឲ្យរដ្ឋជាប់ឆ្នេរពន្លាតខ្ពង់រាបបាតសមុទ្ររបស់ខ្លួនបានត្រឹមរយៈចំណាយ ៣៥០ម៉ាយ។

# ផ្នែកទី៣ ដែនទឹក (ដែនសមុទ្រ)

- ការកំណត់ព្រំដែនទឹក

<u>ខ្ពង់រាបបាតសមុទ្រ</u> នៅក្នុងតំបន់នេះ រដ្ឋម្ចាស់ដែនសមុទ្រមានសមត្ថកិច្ចក្នុងការយកធនធានរ៉ែ (រ៉ែប្រេង ឧស្ម័ន មាស ជាអាទិ៍) និងធនធានជីវចម្រុះផ្សេងៗទៀត។ ជាទូទៅខ្ពង់រាបបាតសមុទ្រជាតំបន់ដែលសម្បូរទៅធនធានធម្មជាតិ។

# ផ្នែកទី៤ ដែនអាកាស

- សញ្ញាណទូទៅ

ដែនអាកាស គឺជាលំហរអាកាសដែលស្ថិតនៅពីលើដែនដីគោក និងដែនទឹករបស់រដ្ឋ។ ស្របពេលមានការរីកចម្រើននៃវិស័យហោះហើររបស់យន្តហោះ នៅដើមសតវត្សទី២០ គេបានបង្កើតឲ្យមានអនុសញ្ញាអន្តរជាតិមួយ គឺអនុសញ្ញាឈីកហ្គោ ឆ្នាំ១៩៤៤។

# ផ្នែកទី៤ ដែនអាកាស

- ការកំណត់ព្រំដែនអាកាស

ការកំណត់ដែនអាកាសរបស់រដ្ឋនៅលើដីគោក មិនដូចការកំណត់ដែនអាកាសរបស់រដ្ឋនៅលើដែនទឹកនោះទេ។ ដែនអាកាសរបស់រដ្ឋនៅលើដែនទឹក គឺគិតត្រឹមខ្សែបន្ទាត់នៃសមុទ្រដែនដីតែប៉ុណ្ណោះ ហើយចាប់ពីសមុទ្រដែនដីទៅខាងក្រៅជាដែនអាកាសអន្តរជាតិ។

# ផ្នែកទី៤ ដែនអាកាស

- ការកំណត់ព្រំដែនអាកាស

មូលហេតុដែលគេកំណត់ដែនអាកាសរបស់រដ្ឋ នៅលើដែនសមុទ្រត្រឹមខ្សែបន្ទាត់នៃសមុទ្រដែនដី គឺគេចង់បើកទូលាយនូវសេរីភាពនៃការហោះហើរ ព្រោះបើដែនអាកាសរបស់រដ្ឋកាន់តែរីកធំនោះសេរីភាពនៃការហោះហើរ កាន់តែរួមតូចៗ

# ផ្នែកទី៤ ដែនអាកាស

- ការកំណត់ព្រំដែនអាកាស

រដ្ឋម្ចាស់ដែនអាកាស មានសិទ្ធិអំណាចពេញលេញ និងផ្តាច់មុខនៅក្នុងលំហរអាកាសរបស់ខ្លួន។ ដូចបានបញ្ជាក់ពីខាងលើ អធិបតេយ្យដែនអាកាសរបស់រដ្ឋលើដែនសមុទ្រ គឺមានត្រឹមសមុទ្រដែនដី ហើយផុតពីតំបន់នេះទៅ ស្ថិតក្នុងដែនសមត្ថកិច្ចរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

# ផ្នែកទី៤ ដែនអាកាស

- ការកំណត់ព្រំដែនអាកាស

ការកំណត់រយៈកំពស់នៃដែនអាកាសរបស់រដ្ឋនៅលើដីគោក និងដែនទឹក គឺបាញ់ត្រង់ឡើងទៅលើរហូតដល់រយៈកំពស់ដែលយន្តហោះអាចហោះហើរបាន។ បើផុតពីរយៈកំពស់នេះទៅ គឺស្ថិតនៅក្នុងការគ្រប់គ្រងនៃនីតិលំហរអាកាស។

# ផ្នែកទី៤ ដែនអាកាស

- ការកំណត់ព្រំដែនអាកាស

នៅក្នុងលំហរដែនអាកាសរបស់ខ្លួន រដ្ឋមានសេរីភាពពេញលេញក្នុងចាត់ចែង និងហាមឃាត់រាល់សកម្មភាពនៃការហោះហើរនៃយន្តហោះបរទេស។ សូមបញ្ជាក់ថា គ្រប់ការហោះហើរទាំងឡាយណាដែលពុំមានការអនុញ្ញាតពីរដ្ឋ នោះគឺជាការរំលោភលើអធិបតេយ្យ និងបូរណភាពដែនដីនៃរដ្ឋ។

មេរៀនទី៩ ស្តីពីរដ្ឋ (ដែនដីនៃរដ្ឋ) បានបញ្ចប់។ សូមអរគុណសម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។